**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៤០ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/ ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ត្រូវបានបង្កើត "សាជីវកម្មធានាឥណទានកម្ពុជា" ដែលសរសេរជាអក្សរកាត់ថា "**ស.ធ.ក.**" និងសរសេរជាភាសាអង់គ្លេសថា Credit Guarantee Corporation of Cambodia (CGCC) ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២ ._**

**ស.ធ.ក.** ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ដែលមានឧបនិស្ស័យជាគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។

**មាត្រា៣ ._**

**ស.ធ.ក.** មានបេសកកម្មផ្តល់សេវាធានាឥណទានប្រកបដោយជំនាញវិជ្ជាជីវៈ ស្របតាមនិយាមអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងទីផ្សារឥណទាន និងជំរុញបរិយាប័ន្នហិរញ្ញវត្ថុ។

**មាត្រា៤ ._**

**ស.ធ.ក.** មានភារកិច្ច ដូចតទៅ÷

- ផ្តល់សេវាធានាឥណទាន

- វាយតម្លៃកម្រិតហានិភ័យ និងគ្រប់គ្រងឱ្យមានការចែករំលែកហានិភ័យលើឥណទាននៅក្នុងប្រតិបត្តិការធានាឥណទាន
- សហការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ដែលចូលរួមក្នុងការផ្តល់សេវាធានាឥណទាន
- គ្រប់គ្រងចំណូល-ចំណាយប្រតិបត្តិការ និងដំណើរការរបស់ខ្លួនឱ្យមាននិរន្តរភាព
- ផ្តល់សេវាគាំទ្រ ជាអាទិ៍ ការកសាងសមត្ថភាព ការប្រឹក្សាយោបល់ ជំនួយបច្ចេកទេសនិងព័ត៌មាន ក្នុងក្របខណ្ឌនៃការផ្តល់សេវាធានាឥណទាន
- ធានាការផ្តល់សេវាធានាឥណទានប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

**មាត្រា៥ ._**

**ស.ធ.ក.** ទទួលបានបុគ្គលភាពគតិយុត្តពេញលេញ ស្របតាមច្បាប់កំណត់ ហើយជាម្ចាស់កម្មសិទ្ធិនៃទ្រព្យទាំងឡាយ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ។

**មាត្រា៦ ._**

ទីស្នាក់ការកណ្តាលរបស់ **ស.ធ.ក.** ស្ថិតនៅរាជធានីភ្នំពេញ និងអាចមានសាខាតាមការចាំបាច់។

## ជំពូកទី ២
## ប្រភពមូលនិធិធានាឥណទាន និងកម្រៃធានាឥណទាន

**មាត្រា៧ ._**

ប្រភពទុនរបស់ **ស.ធ.ក.** រួមមាន÷

- ដើមទុនចុះបញ្ជីដំបូងចំនួន ៨១០ពាន់លានរៀល សមមូលនឹង ២០០លានដុល្លារអាមេរិកជាថវិការដ្ឋ
- ដើមទុនបន្ថែមពីប្រភពថវិការដ្ឋ ទៅតាមការចាំបាច់របស់រាជរដ្ឋាភិបាល
- ចំណូលពីប្រតិបត្តិការនៃសេវាធានាឥណទាន
- ដើមទុនពីដៃគូអភិវឌ្ឍន៍ និង/ឬវិស័យឯកជន
- ធនធានដែលបានមកពីការខ្ចី ការបោះផ្សាយមូលបត្រ និងការចូលរួមចំណែកពីប្រភពផ្សេងៗទៀត។

**មាត្រា៨ ._**

ការផ្តល់សេវាធានាឥណទាន ត្រូវកំណត់កម្រៃសេវាធានាឥណទានដែលមានលក្ខណៈសមរម្យប្រកួតប្រជែងនិងមានភាពទាក់ទាញ និងការគាំទ្រពីការចូលរួមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុន/សហគ្រាស។

យន្តការនៃការកំណត់កម្រៃសេវាធានាឥណទាន និងនីតិវិធីនៃការផ្តល់សេវាធានាឥណទានត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល **ស.ធ.ក.** និងស្នើសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កម្រៃសេវាធានាឥណទានដែលទទួលបាន ត្រូវយកទៅប្រើប្រាស់សម្រាប់កិច្ចប្រតិបត្តិការ និងការបង្កើនដើមទុននៃ **ស.ធ.ក.** តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ស.ធ.ក.** និងអនុម័តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៩ .-**

**ស.ធ.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | ប្រធាន |
| - តំណាងធនាគារជាតិនៃកម្ពុជា | ០១ រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| - អគ្គនាយករបស់ **ស.ធ.ក.** | ០១ រូប | សមាជិក |
| - តំណាងបុគ្គលិករបស់ **ស.ធ.ក.** | ០១ រូប | សមាជិក |
| - តំណាងឯករាជ្យពីវិស័យឯកជន | ០១ រូប | សមាជិក |

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមានសមាសភាពពីវិស័យសាធារណៈ លើកលែងតែតំណាងបុគ្គលិកត្រូវតែងតាំងសម្រាប់អាណត្តិ៣ឆ្នាំ ហើយអាចបន្តជាថ្មីទៀតបានដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងបុគ្គលិកត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិករបស់ **ស.ធ.ក.**។

សមាសភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិ តាមសំណើរបស់ក្រសួង-ស្ថាប័នតំណាង ក្នុងករណី សមាជិកក្រុមប្រឹក្សាភិបាល មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង-ស្ថាប័ន, តំណាងបុគ្គលិក **ស.ធ.ក.**, ទទួលមរណភាព, សុំលាឈប់ជាលាយលក្ខណ៍អក្សរ, បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

**មាត្រា១០ .-**

ការងារប្រចាំថ្ងៃរបស់ **ស.ធ.ក.** ត្រូវគ្រប់គ្រងដោយ **"អគ្គនាយក"** ០១ រូប ដែលត្រូវបានជ្រើសរើសដោយឈរលើគោលការណ៍នៃការប្រកួតប្រជែង, បើកចំហ, និងតម្លាភាពដោយផ្អែកលើសមត្ថភាព និងបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ អគ្គនាយកត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១ ._**

តួនាទីរបស់ក្រុមប្រឹក្សាភិបាល និងអគ្គនាយក ត្រូវកំណត់ដោយលក្ខន្តិកៈរបស់ **ស.ធ.ក.**។

**មាត្រា១២ ._**

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា១៣ ._**

**ស.ធ.ក.** ត្រូវមានក្របខណ្ឌអភិបាលកិច្ចសាជីវកម្មសមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីធានាប្រសិទ្ធភាព, សុខភាពហិរញ្ញវត្ថុ និងការរីកចម្រើនប្រកបដោយចីរភាពដែលត្រូវមានចែងលម្អិតនៅក្នុងលក្ខន្តិកៈរបស់ **ស.ធ.ក.**។

## ជំពូកទី ៤
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៤ ._**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារពាក់ព័ន្ធទាំងឡាយ។

**មាត្រា១៥ ._**

រៀងរាល់ឆ្នាំ មុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការប្រចាំឆ្នាំរបស់ **ស.ធ.ក.** តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៦ ._**

រដ្ឋធានាចំពោះហានិភ័យណាដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៧ ._**

រយៈពេល ១៥ ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក **ស.ធ.ក.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាលរួមជាមួយគម្រោងផែនការអាជីវកម្ម និង/ឬរបាយការណ៍ប្រតិបត្តិការ និង/ឬរបាយ-ការណ៍ហិរញ្ញវត្ថុ និង/ឬឯកសារពាក់ព័ន្ធផ្សេងទៀតតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ._**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៤ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ